# សេចក្តីនៅក្នុងវីដេអូអំពីការវិលត្រឡប់មកសាលារៀនវិញរបស់ DRH សម្រាប់ក្រុមគ្រួសារ

សួស្តីក្រុមគ្រួសាររបស់ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា។ ថ្ងៃពុធ ទី ២ ខែកញ្ញា គឺជាថ្ងៃចូលរៀនដំបូង ហើយយើងរីករាយក្នុងការរោទ៍កណ្តឹងតាមកុំព្យូទ័រ PHL និង ស្វាគមន៍ សិស្សានុសិស្សទាំងអស់របស់យើងមកកាន់ឆ្នាំសិក្សាថ្មី ដើម្បី សិក្សា និង មានការរីកចម្រើន។ ដូចអ្វីដែលខ្ញុំបាននិយាយពីមុន ឆ្នាំសិក្សានេះនឹងមិនដូចឆ្នាំសិក្សាមុនៗនោះទេ។

រឿងមួយដែលថ្មីនិងប្លែកនោះគឺ សិស្សថ្នាក់មុនមត្តេយ្យ ដល់ថ្នាក់ទី ១២ ទាំងអស់ នឹងចាប់ផ្តើមសិក្សាតាមកុំព្យូទ័រ ៥ ថ្ងៃ ក្នុងមួយសប្តាហ៍ ជាមួយគ្រូមកពីសាលាដែលពួកគេបានចុះឈ្មោះចូលរៀន។ គ្មានការសង្ស័យអ្វីទេថា **នេះគឺជាឆ្នាំសិក្សាពិតប្រាកដ**។ ហេតុនេះ វា**មានសារៈសំខាន់ខ្លាំងណាស់**សម្រាប់សិស្សានុសិស្ស**ទាំងអស់** ចាប់ផ្តើមឆ្នាំសិក្សាយ៉ាងខ្លាំងក្លា ដោយចុចចូលទៅក្នុងឧបករណ៍កុំព្យូទ័ររបស់ពួកគេ**ទាន់ពេលវេលា ជារៀងរាល់ថ្ងៃ**... ចាប់ផ្តើមតាំងពី**ថ្ងៃដំបូង**។ នោះមានន័យថាត្រូវរៀបចំទុកជាមុន ដោយការ**ដឹង**ពីកាលវិភាគសាលារបស់កូនលោកអ្នក **ធ្វើយ៉ាងណា**ឱ្យកូនរបស់លោកអ្នកមានកុំព្យូទ័រក្រូមប៊ុកដែលអាចប្រើបាន ឬ ឧបករណ៍ឌីជីថលផ្សេងទៀតដើម្បីប្រើក្នុងមួយថ្ងៃៗ ហើយធ្វើយ៉ាងណាលោកអ្នក**ត្រូវតែ**មានអ៊ីនធឺណិត។

បទពិសោធន៍នៃការសិក្សាតាមកុំព្យូទ័រសម្រាប់សិស្សានុសិស្ស មើលទៅ និង មានអារម្មណ៍ ថាខុសគ្នាពីនិទាឃរដូវមុន។ ផ្អែកលើមតិយោបល់ដែលលោកអ្នកបានផ្តល់ឱ្យយើងខ្ញុំ យើងខ្ញុំនឹងធ្វើយ៉ាងណាឱ្យ សិស្សានុសិស្សមានពេលវេលាច្រើនដើម្បី ធ្វើកិច្ចការជាមួយគ្នា ចូលរួមក្នុងការសិក្សាដែលផ្អែកលើគម្រោង ប្រើការសិក្សានៅក្នុងថ្នាក់រៀនរបស់ពួកគេជាមួយបទពិសោធន៍នៃជីវិតពិត និង ទំនាក់ទំនងជាមួយគ្រូ។ យើងក៏បានផ្តល់ការហ្វឹកហ្វឺនបន្ថែមដល់លោកគ្រូអ្នកគ្រូរបស់យើង ដើម្បីពង្រឹងសមត្ថភាពរបស់ពួកគាត់ក្នុងការផ្តល់ការបង្ហាត់បង្រៀនតាមកុំព្យូទ័រ។

ទោះបីជាសាលានឹងបង្រៀនតាមកុំព្យូទ័រទាំងស្រុងក៏ដោយ យើងចង់ស្តារឡើងវិញនូវ អារម្មណ៍ដែលធ្លាប់ស្គាល់ និង ទម្លាប់ សម្រាប់សិស្សានុសិស្សរបស់យើង។ ហេតុនេះជាថ្មីម្តងទៀត វាចាប់ផ្តើមជាមួយពួកគេចុចចូលគ្រប់ថ្នាក់ទាន់ពេលវេលាជារៀងរាល់ថ្ងៃ... ដូចគ្នានឹងអ្វីដែលយើងរំពឹងថាពួកគេនឹងទៅដល់ថ្នាក់រៀនរបស់ពួកគេនៅក្នុងអាគារសាលាជារៀនរាល់ថ្ងៃ។ វត្តមានអវត្តមាន ជាមួយនឹងការដាក់ពិន្ទុ គឺជាផ្នែកដ៏សំខាន់មួយនៃការបង្កើតបរិយាកាសសិក្សាដែល គ្រូ និង សិស្ស រក្សាបាននូវទំនាក់ទំនងដ៏រឹងមាំប្រចាំថ្ងៃ ហើយសិស្សមានអារម្មណ៍ថាមាន ការគាំទ្រ និង ការចូលរួម។

យើងទទួលស្គាល់ថា គ្រួសារខ្លះអាចមានការលំបាកជាមួយការសិក្សាតាមអ៊ីនធឺណិតប្រចាំថ្ងៃរបស់សិស្ស។ សូមជ្រាបថា **យើងខ្ញុំយល់**... ហើយយើងខ្ញុំនៅទីនេះដើម្បីធ្វើការ**ជាមួយ**លោកអ្នក ដើម្បីជួយដល់ជោគជ័យនៃការសិក្សារបស់កូនលោកអ្នក។ បើសិនជាមានឧបសគ្គអ្វីរារាំងដល់ការចូលរួមសិក្សាប្រចាំថ្ងៃរបស់

កូនលោកអ្នក សូមទាក់ទងទៅគ្រូរបស់កូនលោកអ្នក ឬ ផ្ញើអ៊ីម៉ែលទៅ ការិយាល័យ វត្តមានអវត្តមាន និង ការចូគេចសាលា attendanceandtruancy@philasd.org ដើម្បីសុំជំនួយ។

អ្វីដែលច្បាស់ផងដែរនោះ គឺថា សិស្សានុសិស្ស និង ក្រុមគ្រួសារ របស់យើងបានឆ្លងកាត់បញ្ហាដ៏គួរឱ្យកត់សម្គាល់ ដោយសារមេរោគ ខូវីដ-១៩ និង ផលប៉ះពាល់នៃ ការប្រកាន់ពូជសាសន៍ និង វិសមភាព ដែលកំពុងបន្តកើតឡើង។ ហេតុនេះយើងកំពុងធ្វើការជាមួយដៃគូនៅក្នុងតំបន់ដែលគួរឱ្យជឿទុកចិត្ត និង អ្នកជំនាញថ្នាក់ជាតិ ដើម្បីចាប់ផ្តើមគំនិតផ្តួចផ្តើមនៃការព្យាបាលរួមគ្នាសម្រាប់ សិស្សានុសិស្ស និង បុគ្គលិក។

ជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងនេះ សិស្សានុសិស្សទាំងអស់នឹងមានឱកាសជារៀងរាល់ថ្ងៃ ដើម្បីចូលរួមការជួបប្រជុំជាសហគមន៍ ជាមួយ គ្រូ និង មិត្តភក្តិ របស់ពួកគេ និង ចូលរួមក្នុងសកម្មភាពរៀនសូត្រពេញមួយថ្ងៃអំពី មនោសញ្ចេតនានៅក្នុងសង្គម និង ការកសាងទំនាក់ទំនង។ ឧទាហរណ៍ គ្រូអាចណែនាំលំហាត់ស្តីពីការរក្សាសតិ (mindfulness exercises) ដែលបានរៀបចំឡើងដើម្បីជួយ សិស្សានុសិស្សឱ្យចេះ គ្រប់គ្រង និង រៀបចំ អារម្មណ៍ជាច្រើន ដែលពួកគេប្រហែលជាកំពុងជួបប្រទះ។ គ្រូ និង អ្នកផ្តល់ឱវាទ នឹងសហការគ្នាដើម្បីកំណត់ថាតើសិស្សណាដែលត្រូវការជំនួយបន្ថែម ជួយភ្ជាប់ទំនាក់ទំនងឱ្យ សិស្សានុសិស្ស និង ក្រុមគ្រួសារ ទៅនឹងជំនួយផ្សេងៗទៀត ទៅតាមសេចក្តីត្រូវការ។ គេក៏នឹងចាត់តាំងអ្នកផ្តល់ការបម្រើផ្នែកសុខភាពអាកប្បកិរិយាឱ្យទៅសាលានីមួយៗដើម្បីផ្តល់ជំនួយបន្ថែម។

លោកអ្នកអាចស្វែងរកព័ត៌មានបន្ថែមទៀតអំពី ការវិលត្រឡប់មកសាលារៀនវិញ ការណែនាំ និង ប្រភពជំនួយ នៅក្នុងវ៉ិបសៃ **philasd.org/backtoschool** ។

ជាថ្មីម្តងទៀត យើងពិតជារំភើបរីករាយក្នុងការស្វាគមន៍លោកអ្នកមកកាន់ឆ្នាំសិក្សាថ្មីនេះ។